# ព្រះរាជក្រម

នស/រកម/០១០៦/០០៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី ៩ ស្តីពីទំនិញគ្រោះថ្នាក់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គ លើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើពិធីសារទី ៩ ស្តីពីទំនិញគ្រោះថ្នាក់

**មាត្រា ១.–**

អនុម័តយល់ព្រមលើពិធីសារទី ៩ ស្តីពីទំនិញគ្រោះថ្នាក់ ដែលធ្វើនៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី នាថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០២ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០០៦

នស.០៦០១.០២៣ **ព្រះមហាក្សត្រ និងព្រះរាជហត្ថលេខា**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ហត្ថលេខា**

**ស៊ុន ចាន់ថុល**

លេខ: ៣៦. ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង គាន់**

# ពិធីសារទី ៩

# ស្តីពី

# ទំនិញគ្រោះថ្នាក់

# DANGEROUSE GOODS

# ពិធីសារទី ៩
# ទំនិញគ្រោះថ្នាក់

# PROTOCOL 9
# DANGEROUS GOODS

រដ្ឋាភិបាលរបស់ប្រទេស ប្រ៊ុយណេ ដារូសសាឡាម, ព្រះរាជាណាចក្រកម្ពុជា, សាធារណរដ្ឋឥណ្ឌូនេស៊ី, សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ, ម៉ាឡេស៊ី, សហភាពមីយ៉ានម៉ា, សាធារណរដ្ឋហ្វីលីពីន, សាធារណរដ្ឋសិង្ហបុរី, ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលជាប្រទេសសមាជិក នៃសមាគមន៍ប្រជាជាតិអាស៊ី ភាគអគ្នេយ៍ ( ហៅកាត់ថាភាគីចុះកិច្ចសន្យា ) ។

**រំលឹកឡើងវិញ** នូវកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសំរបសំរួលទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខា នៅថ្ងៃទី ១៦ ធ្នូ ១៩៩៨ នៅទីក្រុងហាណូយប្រទេសវៀតណាម ( ហៅកាត់ថាកិច្ចព្រមព្រៀង ) ។

**ទទួលស្គាល់ថា** មាត្រា ២០ និង ២៥ ដែលចែងពីការសំរេចលើការអនុវត្តន៍ពិធីសារផ្សេងៗ នឹងបង្កើតឡើងទៅជាផ្នែករួមបញ្ចូលគ្នានៃកិច្ចព្រមព្រៀង ។

**នៅពេលនេះ, ព្រោះហេតុនេះ, ភាគីចុះកិច្ចសន្យាទាំងឡាយបានឯកភាពដូចតទៅ :**

## មាត្រាទី ១
## និយមន័យ

**សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ :**

ក- "ទំនិញគ្រោះថ្នាក់" "មធ្យោបាយដឹកជញ្ជូន" និង "ការដឹកជញ្ជូនឆ្លងកាត់" ត្រូវមាននិយមន័យដូចដែលបានកំណត់អោយក្នុងកិច្ចព្រមព្រៀង ។

ខ- " និយ័តកម្មជាគំរូរបស់អង្គការសហប្រជាជាតិ " មានន័យថា ជាអនុសាសន៍ អង្គការសហប្រជាជាតិ ស្តីពីការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ ឬជានិយ័តកម្មគំរូម៉ូដែល ។

គ- " ADR " មានន័យថា កិច្ចព្រមព្រៀងអឺរ៉ុបពាក់ព័ន្ធដល់ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ជាអន្តរជាតិតាមផ្លូវថ្នល់

ឃ- " ការកែសំរួលឡើងវិញ ADR " មានន័យថា កែសំរួលសេចក្តីបកស្រាយ នៃកិច្ចព្រមព្រៀងអឺរ៉ុបពាក់ព័ន្ធការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវថ្នល់ ដែលអនុវត្តពីថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០១ ។

ង- " ប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ " មានអត្ថន័យដូចដែលបានកំណត់ក្នុងពិធីសារទី ៣ ស្តីពីប្រភេទ និងបរិមាណយានយន្តតាមផ្លូវគោក អនុលោមទៅតាមកិច្ចព្រមព្រៀង ។

## មាត្រា ២
## ទំហំនៃការអនុវត្តន៍

អនុលោមទៅតាមប្រការទី ២០ នៃកិច្ចព្រមព្រៀង, ភាគីចុះកិច្ចសន្យានៅទីនេះយល់ព្រមធ្វើតាមទៅលើប្រការ ដែលមានចែងក្នុងពិធីសារនេះ លើការធ្វើចលនាទំនិញគ្រោះថ្នាក់ទាំងឡាយ ក្នុងការដឹកជញ្ជូនឆ្លងកាត់ តាមផ្លូវថ្នល់ ( ឬ ផ្លូវហាយវេយរវាងរដ្ឋ ) ដែលបានកំណត់ថាជាផ្លូវដឹកជញ្ជូនឆ្លងកាត់ ដូចមានបញ្ជាក់ក្នុងពិធីសារទី ១ នៃកិច្ចព្រមព្រៀង ។

## មាត្រា ៣
## ការចាត់ថ្នាក់នូវទំនិញគ្រោះថ្នាក់

ទំនិញគ្រោះថ្នាក់ទាំងឡាយ ត្រូវបានគេបែងចែកទៅតាមចំណាត់ថ្នាក់ ឬផ្នែកដូចខាងក្រោម :

ចំណាត់ថ្នាក់ទី ១ : គ្រឿងផ្ទុះ ( Explosives )

ចំណាត់ថ្នាក់ទី ២ : ផ្នែកទី ២-១ : ឧស្ម័នអាចឆេះ ( Flammable Gases )
ផ្នែកទី ២-២ : ឧស្ម័នដែលមិនអាចឆេះ-មិនមានជាតិពុល (Non-flammable, Non-toxic gases )
ផ្នែកទី ២-៣ : ឧស្ម័នពុល ( Toxic gases)

ចំណាត់ថ្នាក់ទី ៣ : វត្ថុរាវអាចឆេះ និងវត្ថុរាវដែលងាយនឹងផ្ទុះ ( Flammable Liquids and desensitized explosives )

ចំណាត់ថ្នាក់ទី ៤ : ផ្នែកទី ៤-១ : វត្ថុរឹងអាចឆេះ, សារធាតុរំឡាយសកម្មនិងវត្ថុធាតុរឹងដែលងាយបង្កឱ្យផ្ទុះ ( Flammable Solids self-reactive substances and solid desensitized explosive)

ផ្នែកទី ៤-២ : សារធាតុដែលអាចមានចំហេះដោយឯកឯង ( Substances liable to spontaneous combustion )

ផ្នែកទី ៤-៣ : សារធាតុទាំងឡាយដែលមានប្រតិកម្មជាមួយទឹកអាចបញ្ចេញឧស្ម័នឆេះ ( Substances which in contact with water emit flammable gases )

ចំណាត់ថ្នាក់ទី ៥ ផ្នែកទី ៥-១ : សារធាតុអុកស៊ីត ( Oxidizing substances )
ផ្នែកទី ៥-២ : សរីរាង្គពែរ៉ុកស៊ីដ ( Organic peroxide )

ចំណាត់ថ្នាក់ទី ៦ : ផ្នែកទី ៦-១ : សារធាតុពុល ( Toxic substances )
ផ្នែកទី ៦-២ : សារធាតុឆ្លង ( Infectious substances )

ចំណាត់ថ្នាក់ទី ៧ : គ្រឿងវិទ្យុសកម្ម ( Radioactive material )

ចំណាត់ថ្នាក់ទី ៨ : សារធាតុដែលស៊ី ឬ កាត់ ( អាស៊ីត) ( Corrosive substances )

ចំណាត់ថ្នាក់ទី ៩ : សារធាតុ និងអង្គធាតុគ្រោះថ្នាក់ផ្សេងទៀត ( Miscellaneous dangerous substances and articles )

ការចាត់ថ្នាក់ទំនិញគ្រោះថ្នាក់ ទៅតាមប្រភេទចំណាត់ថ្នាក់ និងផ្នែកដូចខាងលើ ត្រូវធ្វើឡើងស្របទៅតាមផ្នែកទី ២ នៃគំរូម៉ូដែលបទប្បញ្ញត្តិរបស់អង្គការសហប្រជាជាតិ ឬក៏កំណែរសំរួលជាថ្មីនៃ ADR ។

## មាត្រា ៤

## ការអនុម័ត និយ័តកម្មជាគំរូរបស់អង្គការសហប្រជាជាតិ ADR និងការកែសំរួល ADR

សំរាប់គោលបំណង នៃកិច្ចប្រតិបត្តិពិធីសារនេះ ភាគីចុះកិច្ចសន្យាទាំងឡាយនៅទីនេះទទួលយល់ព្រមចាប់ផ្តើមប្រើប្រាស់និយ័តកម្មទាំងឡាយដែលជាគំរូម៉ូដែលរបស់អង្គការសហប្រជាជាតិ ADR និងការកែសំរួល ADR ដែលជាពិសេសទាក់ទងទៅនិងលក្ខណៈផ្សេងៗដូចខាងក្រោម :

១- ការលំអិតចំណាត់ថ្នាក់ និងផ្នែកទាំងឡាយនៃទំនិញគ្រោះថ្នាក់

២- ការវេចខ្ចប់ និងការដាក់ផ្លាកសញ្ញាសំគាល់ទំនិញគ្រោះថ្នាក់

៣- ការលាបពណ៌យានយន្ត និងវិធីសាស្ត្រក្នុងការវេចខ្ចប់

៤- ឯកសារដឹកជញ្ជូន និងសេចក្តីប្រកាស

៥- ការហ្វឹកហាត់

៦- ការព្រមានប្រឆាំងទល់នឹងភ្លើងឆេះ និង/ ឬក៏ការផ្ទុកទាំងឡាយ ។

## មាត្រា ទី ៥

## ការអនុញ្ញាត

១- ការដឹកជញ្ជូនឆ្លងកាត់នូវទំនិញទាំងឡាយណា ដែលមានចូលក្នុងប្រភេទលក្ខណៈណាមួយ ឬក៏ចំណាត់ថ្នាក់ដូចបានកំណត់ក្នុងមាត្រា ៣ និង បទប្បញ្ញត្តិនៃមាត្រា ៤ នៅក្នុងទីនេះ មិនត្រូវបានគេអនុវត្តដោយអ្នកធ្វើប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ណាមួយឡើយ លើកលែងតែមានការអនុញ្ញាតណាមួយ សំរាប់គោលបំណងបែបនេះ ត្រូវបានគេចេញអោយដោយអាជ្ញាធរពាក់ព័ន្ធទាំងឡាយ នៃភាគីចុះកិច្ចសន្យា ដែលការដឹកជញ្ជូនឆ្លងកាត់ ធ្វើឡើងកាត់តាមដែនដី នៃភាគីនោះ ។

២- ពាក្យសុំសំរាប់ការអនុញ្ញាត ដូចបានអធិប្បាយខាងលើ ត្រូវបានគេធ្វើឡើង ជូនទៅគណៈកម្មាការជាតិសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ នៃភាគីចុះកិច្ចសន្យាដែលពាក់ព័ន្ធ ។

៣- នៅពេលដែលពាក្យសុំមួយ ធ្វើឡើងទៅគណៈកម្មការជាតិសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ នៃភាគីចុះកិច្ចសន្យាដែលពាក់ព័ន្ធ គណៈកម្មាការជាតិសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់នោះ ត្រូវទាក់ទងជាមួយគណៈកម្មាការជាតិសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ នៃភាគីចុះកិច្ចសន្យាម្ខាងទៀត ដែលការដឹកជញ្ជូនឆ្លងកាត់ទាំងឡាយ ធ្វើឡើងកាត់តាមដែនដី នៃភាគីនោះ ។

៤- ការអនុញ្ញាតណាមួយប្រសិនបើមិនបានសរសេរជាភាសាអង់គ្លេស ត្រូវតែភ្ជាប់ដោយការបកប្រែបញ្ជាក់ជាភាសាអង់គ្លេស ដែលចេញអោយដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ។

៥- សំរាប់ជៀសវាងនៃការសង្ស័យ គណៈកម្មាការជាតិសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ មិនត្រូវបានគេចាត់ជាអាជ្ញាធរមានសិទ្ធិអនុម័តក្នុងការអនុញ្ញាត ដូចបានរៀបរាប់អធិប្បាយ ប៉ុន្តែគ្រាន់តែសំរួល និងផ្តល់ការទំនាក់ទំនងរវាងអ្នកស្នើសុំ និង អាជ្ញាធរមានសិទ្ធិផ្តល់ការយល់ព្រម-អនុម័ត ដែលពាក់ព័ន្ធ ។

## មាត្រា ទី ៦

## ការរៀបចំស្ថាប័នទាំងឡាយ

១- កិច្ចប្រជុំនានារបស់មន្ត្រីដឹកជញ្ជូនជាន់ខ្ពស់អាស៊ានត្រូវតែជាអ្នកទទួលខុសត្រូវសំរាប់ការត្រួតពិនិត្យ តាមដានការពិនិត្យមើលឡើងវិញ សំរបសំរួល និង ត្រួតត្រាមើល នូវទិដ្ឋភាពទាំងអស់ ដែលពាក់ព័ន្ធទៅដល់ការអនុវត្តន៍ដោយមានប្រសិទ្ធិភាព នូវពិធីសារនេះ ។

២- កិច្ចប្រជុំរបស់មន្ត្រីដឹកជញ្ជូនជាន់ខ្ពស់អាស៊ាន ត្រូវដាក់ស្នើតាមរយៈលេខាធិការដ្ឋានអាស៊ាន នូវរបាយការណ៍ជាទៀងទាត់ទាំងឡាយ ស្តីពីភាពជឿនលឿន នៃការប្រតិបត្តិរបស់ពិធីសារនេះ ទៅក្រុមប្រឹក្សាភិបាលសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ សំរាប់សកម្មភាពនានាបន្ថែមទៀត ។

៣- លេខាធិការដ្ឋានអាស៊ានត្រូវផ្តល់នូវការទ្រទ្រង់ និងជំនួយបច្ចេកទេសជាចាំបាច់ទៅដល់កិច្ចប្រជុំមន្ត្រីដឹកជញ្ជូនជាន់ខ្ពស់ទាំងឡាយរបស់អាស៊ានក្នុងមុខការ និងការទទួលខុសត្រូវរបស់គេ ទៅតាមពិធីសារនេះ ។

## មាត្រា ៧

## អវសានប្បញ្ញត្តិ

១- ពិធីសារនេះ នឹងត្រូវតំកល់ទុកនៅអគ្គលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកផ្សព្វផ្សាយយ៉ាងរហ័ស នូវច្បាប់ចំលងមួយដែលមានបញ្ជាក់ដូចគ្នានេះ ទៅភាគីចុះកិច្ចសន្យានីមួយៗ ។

២- ពិធីសារនេះ គឺជាការបង្គ្រប់បន្ថែម ពីលើកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសំរួលទំនិញឆ្លងកាត់ដែលបានចុះហត្ថលេខានៅថ្ងៃទី១៦ ធ្នូ ១៩៩៨ នៅទីក្រុងហាណូយប្រទេសវៀតណាម និងក៏ដូចជាវាំងភាគីជាប់កិច្ចសន្យាទាំងឡាយចំពោះពិធីសារនេះ ។ កិច្ចព្រមព្រៀងនិងពិធីសារនេះត្រូវបានគេបញ្ចប់សព្វគ្រប់និងបកស្រាយរួមជាមួយគ្នាដូចជាលិខិតតុបករណ៍តែមួយ ។

៣- ពិធីសារនេះគឺជាកម្មវត្ថុក្នុងការធ្វើសច្ចាប័ន ឬ ការយល់ព្រមដោយភាគីចុះកិច្ចសន្យា ។ លិខិតតុបករណ៍ នៃការធ្វើសច្ចាប័ន ឬ ការយល់ព្រមចូលត្រូវគេតំកល់ទុកនៅជាមួយអគ្គលេខាធិការអាស៊ាន ដែលជាអ្នកផ្តល់ពត៌មានយ៉ាងរហ័សទៅភាគីចុះកិច្ចសន្យានីមួយៗ នូវការតំកល់ទុកនេះ ។

៤- ពិធីសារនេះនឹងត្រូវចូលជាធរមាន ក្នុងពេលដែលការតំកល់ទុកនូវលិខិតតុបករណ៍ នៃការធ្វើសច្ចាប័ន ឬ ការយល់ព្រមធ្វើឡើងពីគ្រប់ភាគីចុះកិច្ចសន្យាទាំងអស់ នៅជាមួយអគ្គលេខាធិការអាស៊ាន ។

៥- ការធ្វើវិសោធនកម្មណាមួយ ទៅលើប្រការទាំងឡាយដែលមានចែងក្នុងពិធីសារនេះ និងឧបសម្ព័ន្ធទាំងឡាយរបស់វាសំរេចទៅបានតាមរយៈការព្រមព្រៀងគ្នាពីគ្រប់ភាគីចុះកិច្ចសន្យាទាំងអស់ ។

៦- សេចក្តីយោងក្នុងពិធីសារនេះ ទៅតាមនិយ័តកម្មជាគំរូម៉ូរបស់អង្គការសហប្រជាជាតិ ADR និងការកែសំរួល ADR និងប្រែក្លាយសេចក្តីបកស្រាយអធិប្បាយ ទៅតាមសេចក្តីបកស្រាយអធិប្បាយ ដែលមានអាទិភាពស្រាប់ នៃ

លិខិតតុបករណ៍ទាំងនេះចាប់ពីថ្ងៃចុះហត្ថលេខាលើពិធីសារនេះ ។ ការអនុវត្តន៍ នៃការបកស្រាយ ឬ ការកែប្រែនៅថ្ងៃខាងមុខ ទៅលើនិយ័តកម្មជាគំរូម៉ូដែលរបស់អង្គការសហប្រជាជាតិ ADR និងការកែសំរួល ADR ត្រូវតែមានការឯកភាពពីគ្រប់ភាគីចុះកិច្ចសន្យាទាំងអស់ ។

ជាសក្ខីភាពនៅទីនេះ ហត្ថលេខីខាងក្រោម បានទទួលសិទ្ធិប្រទានយ៉ាងត្រឹមត្រូវ ដើម្បីចុះហត្ថលេខាពីរដ្ឋាភិបាលរបស់ពួកគេទាំងឡាយរៀងៗខ្លួន បានចុះហត្ថលេខាលើពិធីសារទី ៩ ស្តីពីទំនិញគ្រោះថ្នាក់ ដើម្បីអនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសំរបសំរួលទំនិញឆ្លងកាត់ ។

ធ្វើនៅទីក្រុង ហ្សាការតា នៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០២ ជាភាសាអង់គ្លេសតែមួយច្បាប់គត់ ។

**តំណាងរដ្ឋាភិបាលព្រុយណេដារូសាឡឹម**

PENIN DATO HAJI ZAKARIA SULAIMAN
រដ្ឋមន្ត្រី គមនាគមន៍

**តំណាងរដ្ឋាភិបាល ព្រះរាជាណាចក្រកម្ពុជា**

KHY TAINGLIM
រដ្ឋមន្ត្រីសាធារណការ និងដឹកជញ្ជូន

**តំណាងរដ្ឋាភិបាល សាធារណរដ្ឋឥណ្ឌូណេស៊ី**

AGUM GUMELAR
រដ្ឋមន្ត្រី គមនាគមន៍

**តំណាងរដ្ឋាភិបាល សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ**

BOUATHONG VONGLOKHAM
រដ្ឋមន្ត្រី គមនាគមន៍ ដឹកជញ្ជូន ប្រៃសណីយ៍ និងសំណង់

តំណាងរដ្ឋាភិបាល ម៉ាឡេស៊ី

DATO SERI DR. LING LIONG SIK

រដ្ឋមន្ត្រី ដឹកជញ្ជូន

តំណាងរដ្ឋាភិបាល សហភាពមីយ៉ាន់ម៉ា

MAJ GEN HLA MYINT SWE

រដ្ឋមន្ត្រី ដឹកជញ្ជូន

តំណាងរដ្ឋាភិបាល សាធារណរដ្ឋហ្វីលីពីន

ARTURO T.VALDEZ

រដ្ឋលេខាធិការ ដឹកជញ្ជូន និងគមនាគមន៍

តំណាងរដ្ឋាភិបាល សាធារណរដ្ឋសិង្ហបុរី

YEO CHEOW TONG

រដ្ឋមន្ត្រី គមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន

តំណាងរដ្ឋាភិបាល ព្រះរាជាណាចក្រថៃឡង់ដ៍

NIKORN CHAMNONG

អនុរដ្ឋមន្ត្រី ដឹកជញ្ជូន និងគមនាគមន៍

តំណាងរដ្ឋាភិបាល សាធារណរដ្ឋសង្គមនិយមវៀតណាម

DR.TRAN DOAN THO

អនុរដ្ឋមន្ត្រី ដឹកជញ្ជូន